# ជំពូកទី ១៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច និងបញ្ហាប្រឈម

ឆ្នាំ២០២៤ គឺជាឆ្នាំដែលកំណើនសេដ្ឋកិច្ចពិភពលោកមានភាពរឹងមាំហើយអតិផរណាបន្តថមថយ ទោះបីជាមានការប្រឈមនឹងភាពមិនប្រាកដប្រជាមួយចំនួនក៏ដោយ។ សេដ្ឋកិច្ចពិភពលោកបានឈានទៅក្នុងដំណាក់កាលថ្មីមួយ ដែលធនាគារកណ្តាលធំៗបានចាប់ផ្តើមបន្ធូរបន្ថយនយោបាយរូបិយវត្ថុ បន្ទាប់ពីការរឹតត្បិតអស់រយៈពេលបីឆ្នាំ។ ទោះយ៉ាងណា បញ្ហាប្រឈមដែលបានកើតឡើងនៅក្នុងឆ្នាំ រួមមាន ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយដែលបានបង្កឱ្យមានការកើនឡើងថ្លៃទំនិញក្នុងអំឡុងពេលមួយចំនួន និងយុទ្ធនាការបោះឆ្នោតជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិកដែលបានបង្កការព្រួយបារម្ភអំពីគោលនយោបាយពាណិជ្ជកម្មនិងសេដ្ឋកិច្ចផ្សេងៗទៀតរបស់សហរដ្ឋអាមេរិកនាពេលអនាគត។ បើទោះជាមានបញ្ហាប្រឈមទាំងនេះ សេដ្ឋកិច្ចសហរដ្ឋអាមេរិកបានបង្ហាញពីភាពខ្លាំងក្លា ដែលគាំទ្រដោយភាពរឹងមាំនៃចំណាយរបស់អ្នកប្រើប្រាស់និងការវិនិយោគក្នុងវិស័យបច្ចេកវិទ្យា ស្របពេលដែលដែលអតិផរណាបានថយចុះទៅកម្រិតទាបបំផុត ចាប់តាំងពីការចាប់ផ្តើមនៃវិបត្តិជំងឺកូវីដ-១៩។ ទោះយ៉ាងណា សេដ្ឋកិច្ចតំបន់អឺរ៉ុបបានបន្តរក្សាអត្រាកំណើនក្នុងកម្រិតទាបបន្តិច។

សេដ្ឋកិច្ចប្រទេសអាស៊ាន+៣ សម្រេចបានកំណើនថេរក្នុងអត្រា ៤,៣ ភាគរយនៅឆ្នាំ២០២៤ បន្ទាប់ពីកើនឡើងក្នុងអត្រា ៤,៤ ភាគរយនៅឆ្នាំ២០២៣។ តម្រូវការក្នុងស្រុកបន្តជាកត្តាចម្បងក្នុងការជំរុញកំណើន ដែលគាំទ្រដោយភាពរឹងមាំនៃទីផ្សារការងារ និងការងើបឡើងវិញនៃការវិនិយោគ។ ការកើនឡើងវិញនៃការនាំចេញ ជាពិសេសក្នុងវិស័យសីមីកុងឌុកទ័រ និងពាណិជ្ជកម្មសេវាកម្ម បានផ្តល់សន្ទុះបន្ថែមដល់កំណើនសេដ្ឋកិច្ច។ អតិផរណាបានបន្តថមថយ បើទោះជាតម្លៃថាមពលដោយសារស្ថានភាពផ្គត់ផ្គង់និងថ្លៃដឹកជញ្ជូនបានកើនឡើងនៅអំឡុងពេលខ្លះក៏ដោយ។ ទីផ្សារហិរញ្ញវត្ថុមានភាពរឹងមាំបន្ថែមទៀតនៅពាក់កណ្តាលដើមឆ្នាំ ប៉ុន្តែស្ថានភាពទីផ្សារមានការប្រែប្រួលនៅពាក់កណ្តាលចុងឆ្នាំ ដោយទីផ្សារភាគហ៊ុនបកមកគ្រាមុន ហើយអត្រាការប្រាក់នៃមូលបត្របំណុលបានកើនឡើង។ បើទោះជាមានការកើនឡើងនៃភាពមិនច្បាស់លាស់នៃស្ថានភាពពិភពលោកនិងការប្រែប្រួលនៃស្ថានភាពទីផ្សារហិរញ្ញវត្ថុ ទុនបម្រុងអន្តរជាតិរបស់ប្រទេសក្នុងតំបន់បន្តមានកម្រិតខ្ពស់គ្រប់គ្រាន់ ដែលបានបង្កើនភាពធន់ទៅនឹងកត្តាខាងក្រៅ។

សេដ្ឋកិច្ចប្រទេសអាស៊ាន+៣ រំពឹងថានឹងរក្សាកំណើនក្នុងអត្រាលើសពី ៤ ភាគរយ នៅឆ្នាំ២០២៥ និង ឆ្នាំ២០២៦។ តម្រូវការក្នុងស្រុកនឹងបន្តជាសសរស្តម្ភដ៏សំខាន់នៃកំណើន ដែលគាំទ្រដោយភាពកាន់តែប្រសើរឡើងនៃសកម្មភាពវិនិយោគ ស្របពេលដែលតម្រូវការខាងក្រៅ ជាពិសេសពីវិស័យបច្ចេកវិទ្យានិងទេសចរណ៍ នឹងផ្តល់ការគាំទ្របន្ថែមដល់កំណើនសេដ្ឋកិច្ច។ ទោះយ៉ាងណា ការព្យាករនេះប្រឈមនឹងភាពមិនប្រាកដប្រជា ជាពិសេសពីគោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចតំបន់។ ក្នុងរយៈពេលមធ្យម ប្រទេសអាស៊ាន+៣ រំពឹងថានឹងនៅតែជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោក ដោយនឹងចូលរួមចំណែកប្រមាណ ៤៣ ភាគរយ ទៅក្នុងកំណើនសេដ្ឋកិច្ចពិភពលោក ទាបជាងបន្តិចបើធៀបនឹងកម្រិតជាមធ្យមកាលពីមុនវិបត្តិជំងឺកូវីដ-១៩។ ទន្ទឹមនេះដែរ អតិផរណារំពឹងថានឹងកើនឡើងបន្តិច ប៉ុន្តែបន្តមានកម្រិតទាបប្រមាណ ១,៧ ភាគរយ ក្នុងឆ្នាំ២០២៥ និង ឆ្នាំ២០២៦។

ទស្សនវិស័យសម្រាប់រយៈពេលខ្លីសម្រាប់ប្រទេសអាស៊ាន+៣ អាចនឹងទទួលរងឥទ្ធិពលពីហានិភ័យមួយចំនួន។ ហានិភ័យចម្បងជាងគេគឺការកើនឡើងនៃគោលនយោបាយពាណិជ្ជកម្មការពារនិយមពីសហរដ្ឋអាមេរិក ដែលអាចធ្វើឱ្យមានការរំខានដល់លំហូរពាណិជ្ជកម្មនិងការថយចុះកំណើនសេដ្ឋកិច្ចក្នុងតំបន់។ ហានិភ័យសំខាន់ផ្សេងទៀត រួមមាន ការរឹតត្បិតបន្ថែមទៀតនៃស្ថានភាពហិរញ្ញវត្ថុពិភពលោក កំណើនយឺតជាងមុននៅបណ្តាប្រទេសសេដ្ឋកិច្ចធំៗ និងការកើនឡើងនៃថ្លៃទំនិញដោយសារភាពតានតឹងភូមិសាស្ត្រនយោបាយឬបញ្ហាអាកាសធាតុ។ សម្រាប់រយៈពេលវែង បញ្ហាប្រឈមជារចនាសម្ព័ន្ធ ដូចជា កំណើននៃសមាមាត្រប្រជាជនវ័យចំណាស់ ការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលខ្លាំងនៃបច្ចេកវិទ្យា នឹងបន្តផ្តល់ជាហានិភ័យដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ។

ទស្សនវិស័យមូលដ្ឋានជាវិជ្ជមានផ្តល់ឱកាសក្នុងការកសាងឡើងវិញនូវលំហរគោលនយោបាយ បើទោះជាអ្នកដាក់ចេញនូវគោល-នយោបាយត្រូវប្រឈមនឹងការកើនឡើងនៃភាពមិនច្បាស់លាស់ពីកត្តាខាងក្រៅ។ ខណៈដែលគោលនយោបាយសារពើពន្ធពង្រឹងការគ្រប់គ្រងថវិកានិងនយោបាយរូបិយវត្ថុវិត្ថារកម្មត្រូវបានអនុវត្តក្នុងឆ្នាំ២០២៤ បញ្ហាប្រឈមគោលនយោបាយក៏កាន់តែមានភាព

*នេះជាការបកប្រែពីអត្ថបទដើមជាភាសាអង់គ្លេស ក្នុងគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា សូមយោងទៅអត្ថបទដើមជាភាសាអង់គ្លេស។*

ស្មុគស្មាញ។ នាពេលខាងមុខ គោលនយោបាយអាចផ្តោតលើការពង្រឹងភាពធន់រយៈពេលវែង ទន្ទឹមនឹងការរក្សាភាពបត់បែនក្នុងការដោះស្រាយបញ្ហាប្រឈមសម្រាប់រយៈពេលខ្លី ជាមួយនឹងគោលនយោបាយចម្រុះដែលសមស្របទៅតាមស្ថានភាពនិងបញ្ហារបស់ប្រទេសនីមួយៗ។ ចំពោះសារពើពន្ធ គោលនយោបាយត្រូវសំដៅធ្វើឱ្យមានតុល្យភាពរវាងការពង្រឹងឡើងវិញនូវទ្រនាប់សារពើពន្ធនឹងការរក្សាសមត្ថភាពសម្រាប់គាំទ្រការងើបឡើងវិញនៃកំណើនសេដ្ឋកិច្ច។ សម្រាប់នយោបាយរូបិយវត្ថុ អាជ្ញាធរត្រូវកំណត់កែសម្រួលគោលនយោបាយប្រកបដោយភាពប្រុងប្រយ័ត្នដោយផ្អែកលើស្ថានភាពក្នុងស្រុក ទន្ទឹមនឹងការបន្តមានភាពប្រុងប្រយ័ត្នចំពោះហានិភ័យទៅលើស្ថិរភាពហិរញ្ញវត្ថុនិងសម្ពាធពីកត្តាខាងក្រៅក្នុងបរិបទនៃការប្រែប្រួលស្ថានភាពហិរញ្ញវត្ថុពិភពលោក។

**អាស៊ាន+៣៖ ការប៉ាន់ស្មានកំណើនសេដ្ឋកិច្ច និងអតិផរណា ដោយ AMRO និងការព្យាករសម្រាប់ ឆ្នាំ២០២៥–២០២៦**
(គិតជាភាគរយ ឆ្នាំលើឆ្នាំ)

| ប្រទេស | កំណើនសេដ្ឋកិច្ច | | | អតិផរណា | | |
|---|---|---|---|---|---|---|
| | ២០២៤ ប៉ា. | ២០២៥ ព្យា. | ២០២៦ ព្យា. | ២០២៤ ប៉ា. | ២០២៥ ព្យា. | ២០២៦ ព្យា. |
| **អាស៊ាន+៣** | **៤,៣** | **៤,២** | **៤,១** | **១,២** | **១,៧** | **១,៧** |
| **ប្រទេស+៣** | **៤,១** | **៤,១** | **៤,០** | **០,៧** | **១,៤** | **១,៥** |
| ចិន | ៥.០ | ៤,៨ | ៤,៧ | ០,២ | ១,១ | ១,៣ |
| ហុងកុង | ២,៥ | ២,៤ | ២,៣ | ១,៧ | ២,២ | ២,០ |
| ជប៉ុន | ០,១ | ១,៣ | ១,០ | ២,៧ | ២,៥ | ២,១ |
| កូរ៉េ | ២,០ | ១,៨ | ១,៩ | ២,៣ | ១,៩ | ១,៨ |
| **អាស៊ាន** | **៤,៩** | **៤,៨** | **៤,៧** | **៣,០** | **៣,១** | **២,៨** |
| ប្រ៊ុយណេ | ៥,០ | ៣,០ | ៣,០ | -០,៤ | ០,៩ | ០,៧ |
| កម្ពុជា | ៦,០ | ៥,៨ | ៦,០ | ០,៨ | ១,៥ | ២,៥ |
| ឥណ្ឌូនេស៊ី | ៥,០ | ៥,០ | ៥,១ | ២,៣ | ២,៥ | ២,៥ |
| ឡាវ | ៤,៥ | ៤,៦ | ៤,៦ | ២៣,១ | ១៥,០ | ៨,៥ |
| ម៉ាឡេស៊ី | ៥,១ | ៤,៧ | ៤,៥ | ១,៩ | ២,៧ | ២,៥ |
| មីយ៉ាន់ម៉ា | ៣,២ | ១,០ | ១,០ | ២៧,៥ | ២៥,០ | ១៨,០ |
| ហ្វីលីពីន | ៥,៧ | ៦,៣ | ៦,៣ | ៣,២ | ៣,៣ | ៣,២ |
| សិង្ហបុរី | ៤,៤ | ២,៧ | ២,៤ | ២,៤ | ១,៨ | ១,៨ |
| ថៃ | ២,៥ | ៣,១ | ៣,០ | ០,៧ | ១,៣ | ១,៥ |
| វៀតណាម | ៧,១ | ៦,៥ | ៦,២ | ៣,៦ | ៣,៥ | ៣,០ |

ប្រភព៖ ក្រសួង-ស្ថាប័នជាតិ តាមរយៈ CEIC និង Haver Analytics; ការប៉ាន់ស្មាន និងព្យាកររបស់ AMRO។
ចំណាំ៖ ប៉ាន់ = ប៉ាន់ស្មាន; ព្យា = ព្យាករ, កំណើនសេដ្ឋកិច្ច និងអតិផរណារបស់ប្រទេសមីយ៉ាន់ម៉ាគឺផ្អែកលើឆ្នាំសារពើពន្ធ ដែលចាប់ផ្តើមពីថ្ងៃទី ១ ខែមេសា ដល់ថ្ងៃទី ៣១ ខែមីនា។ ការប៉ាន់ស្មាននិងការព្យាករអតិផរណាគឺទៅលើមធ្យមប្រចាំឆ្នាំ។ ការគណនាកំណើននិងអតិផរណាក្នុងតំបន់ត្រូវបានប៉ាន់ស្មានដោយប្រើមធ្យមទម្ងន់នៃ ផ.ស.ស ឆ្នាំ២០២៤ តាមមូលដ្ឋានយុគភាពអំណាចទិញ ។

*នេះជាការបកប្រែពីអត្ថបទដើមជាភាសាអង់គ្លេស ក្នុងគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា សូមយោងទៅអត្ថបទដើមជាភាសាអង់គ្លេស។*

EN
ID
MS
ZH
JA
KM
KO
LO
MY
TH
VI

# ជំពូកទី ២៖ អតិផរណាក្នុងតំបន់អាស៊ាន+៣ ៖ ការប្រែប្រួលនៃកត្តានានា និងឥទ្ធិពលទៅលើការដាក់ចេញគោលនយោបាយ

ក្រោយរយៈពេលជាងពីរទសវត្សរ៍នៃស្ថិរភាពនិងកម្រិតទាបនៃអតិផរណាក្នុងតំបន់អាស៊ាន+៣ ប្រទេសក្នុងតំបន់បានជួបនឹងការកើនឡើងនៃអតិផរណាក្នុងឆ្នាំ២០២១ ដោយសារវិបត្តិជំងឺកូវីដ-១៩ និងការរាំងស្ទះខ្សែច្រវ៉ាក់ផ្គត់ផ្គង់ពិភពលោក។ ទោះយ៉ាងណា ការកើនឡើងនេះមានកម្រិតទាបនិងមានរយៈពេលខ្លីបើធៀបនឹងតំបន់ផ្សេងៗ ដែលធ្វើឱ្យការខាតបង់ទៅលើសុខុមាលភាពមានកម្រិតតិចតួច។ ខណៈគ្រាមុន ការកើនឡើងនៃថ្លៃទំនិញប្រើប្រាស់ពិភពលោកបានជំរុញឱ្យមានការកើនឡើងថ្លៃជាទូទៅ អតិផរណាបានថមថយនៅចុងឆ្នាំ២០២២ ដោយសារថ្លៃទំនិញប្រើប្រាស់ថយចុះ និងខ្សែច្រវ៉ាក់ផ្គត់ផ្គង់មានភាពប្រសើរឡើងវិញ។ បន្ថែមលើនេះ កត្តាដែលមានឥទ្ធិពលលើអតិផរណាមានការប្រែប្រួលក្រោយវិបត្តិជំងឺកូវីដ-១៩ ដោយនៅគ្រាមុន អតិផរណានៃទំនិញជាកត្តាជំរុញកំណើនថ្លៃ ខណៈអតិផរណានៃសេវាកម្មក្លាយជាកត្តាសំខាន់ក្នុងគ្រានៃការថមថយអតិផរណា។ បើទោះជាមានការប្រែប្រួលនេះ អតិផរណារំពឹងទុកត្រូវបានរក្សាឱ្យមានលំនឹងល្អ ដែលបង្ហាញពីការជឿជាក់ទៅលើស្ថិរភាពថ្លៃ។

ការវិភាគបង្ហាញពីការផ្លាស់ប្តូរតួនាទីគ្នារវាងកត្តាផ្គត់ផ្គង់និងតម្រូវការនៅក្នុងតំបន់។ កត្តាផ្គត់ផ្គង់បានក្លាយជាកត្តាសំខាន់ជាង សម្រាប់ទាំងអតិផរណាស្នូល និងអតិផរណារួម ក្នុងអំឡុងឆ្នាំ២០២១-២០២២ ជាពិសេសតាមរយៈថ្លៃទំនិញប្រើប្រាស់ពិភពលោក និងការរអាក់រអួលនៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់។ នៅពេលដែលសម្ពាធខាងក្រៅថយចុះនៅចុងឆ្នាំ២០២២ កត្តាតម្រូវការបានក្លាយជាកត្តាសំខាន់ក្នុងអំឡុងពេលនៃការបើកឡើងវិញនៃសេដ្ឋកិច្ច។ សេដ្ឋកិច្ចប្រទេស+៣ (រួមមាន ចិន ហុងកុង ជប៉ុន និងកូរ៉េ) មានអតិផរណាថមថយជាបន្តបន្ទាប់ចាប់ពីចុងឆ្នាំ២០២២ មកកម្រិតជាមធ្យមក្រោម ១ ភាគរយនៅមុនពាក់កណ្តាលឆ្នាំ២០២៣ ខណៈដែលប្រទេសអាស៊ានបន្តមានអតិផរណាក្នុងកម្រិតខ្ពស់ជាង ដោយសារតែការងើបឡើងវិញខ្លាំងជាងនៃតម្រូវការក្នុងស្រុក។

ប្រទេសអាស៊ាន+៣ បានប្រើជាចម្រុះនូវនយោបាយរូបិយវត្ថុនិងវិធានការផ្សេងៗទៀត ដើម្បីគ្រប់គ្រងសម្ពាធអតិផរណាបានយ៉ាងមានប្រសិទ្ធភាព។ ចាប់តាំងពីឆ្នាំ២០២២ ការរឹតត្បឹតស្ថានភាពរូបិយវត្ថុ បានដើរតួនាទីសំខាន់ក្នុងការរក្សាលំនឹងអតិផរណារំពឹងទុក និងការគ្រប់គ្រងសម្ពាធតម្រូវការ។ ទន្ទឹមនេះ វិធានការផ្នែកសារពើពន្ធ ដូចជាការឧបត្ថម្ភធនទៅលើថាមពលនិងម្ហូបអាហារ ការបើកសាច់ប្រាក់ឧបត្ថម្ភ និងការកែសម្រួលពន្ធ បានជួយទប់ស្កាត់ការកើនឡើងនៃថ្លៃ និងផ្តល់ការគាំទ្រដ៏សំខាន់ដល់ក្រុមគ្រួសារ។ វិធានការកែសម្រួលទៅលើកត្តាផ្គត់ផ្គង់ដទៃទៀត ដូចជា ការគ្រប់គ្រងថ្លៃលើទីផ្សារ ការគ្រប់គ្រងការទិញស្តុកទុក និងវិធានការលក់ដូរផ្សេងទៀត បានធានាថា ទំនិញចាំបាច់នៅតែមានសម្រាប់ផ្គត់ផ្គង់និងមានតម្លៃសមរម្យ។

បទពិសោធន៍ពីប្រទេសអាស៊ាន+៣ បានផ្តល់ជាមេរៀនសំខាន់ៗសម្រាប់ការគ្រប់គ្រងអតិផរណា ក្នុងបរិបទនៃការប្រែប្រួលកត្តាផ្គត់ផ្គង់និងតម្រូវការដែលមានលក្ខណៈស្មុគស្មាញ។ គោលនយោបាយឆ្លើយតបដែលមានប្រសិទ្ធភាពអាស្រ័យលើការវិភាគឱ្យបានត្រឹមត្រូវអំពីកត្តាជំរុញអតិផរណា និងការប្រើប្រាស់គោលនយោបាយចម្រុះបានសមស្រប។ ខណៈដែលនយោបាយរូបិយវត្ថុនៅតែជាឧបករណ៍សំខាន់សម្រាប់ការគ្រប់គ្រងតម្រូវការ និងការធ្វើឱ្យមានលំនឹងនៃការរំពឹងទុក វិធានការចំគោលដៅផ្សេងទៀតត្រូវបានបង្ហាញថាមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាផ្គត់ផ្គង់ ទប់ស្កាត់ការឡើងថ្លៃខ្ពស់នៃទំនិញចាំបាច់ និងការពារក្រុមគ្រួសារដែលងាយរងគ្រោះ។

នាពេលខាងមុខ ការគ្រប់គ្រងអតិផរណានឹងក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំង ដោយសារមានការផ្លាស់ប្តូរជារចនាសម្ព័ន្ធ ដូចជា ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ការប្រែប្រួលប្រជាសាស្ត្រ និងការប្រែប្រួលអាកាសធាតុដែលបង្កើនហានិភ័យដល់ភាពរអាក់រអួលផ្នែកផ្គត់ផ្គង់។ ធនាគារកណ្តាលអាចនឹងត្រូវចាត់វិធានការឆ្លើយតបកាន់តែខ្លាំងទៅលើបញ្ហាផ្គត់ផ្គង់ ប្រសិនបើហានិភ័យនៃអតិផរណារំពឹងទុកមិនត្រូវបានរក្សាឱ្យមានលំនឹង ជាពិសេសនៅពេលដែលភាពរអាក់រអួលនៃការផ្គត់ផ្គង់កើតឡើងកាន់តែញឹកញាប់និងមានរយៈពេលយូរ។ ការធ្វើឱ្យប្រសើរឡើងនៃការតាមដាន គឺមានសារៈសំខាន់ក្នុងការពិនិត្យឱ្យបានត្រឹមត្រូវទៅលើកត្តាផ្គត់ផ្គង់និងតម្រូវការបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យនៃការយឺតយ៉ាវក្នុងការដាក់ចេញជាវិធានការឆ្លើយតប។ ទោះយ៉ាងណា វិធានការឆ្លើយតបទាំងនោះត្រូវតែថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ ព្រោះការរឹតត្បឹតនយោបាយរូបិយវត្ថុដើម្បីទប់ស្កាត់អតិផរណាដោយសារកត្តាផ្គត់ផ្គង់ អាចនឹងបង្កឱ្យមានការធ្លាក់ចុះសេដ្ឋកិច្ច។ ការកសាងទ្រនាប់គោលនយោបាយ និងការពង្រឹងសមត្ថភាពក្នុងការតាមដាននិងត្រួតពិនិត្យ នឹងជាកិច្ចការដ៏សំខាន់សម្រាប់ដោះស្រាយនូវបញ្ហាប្រឈមដែលកើតមានឡើងទាំងនេះប្រកបដោយប្រសិទ្ធភាព។

*នេះជាការបកប្រែពីអត្ថបទដើមជាភាសាអង់គ្លេស ក្នុងគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា សូមយោងទៅអត្ថបទដើមជាភាសាអង់គ្លេស។*

# ជំពូកទី ៣៖ កំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលវែងក្នុងតំបន់អាស៊ាន+៣៖ ទស្សនវិស័យ និងគោលនយោបាយ

តំបន់អាស៊ាន+៣ នៅតែជាមូលដ្ឋានជំរុញដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចពិភពលោកក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ទៅមុខ។ ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចក្នុងតំបន់នេះបានថមថយចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកល ហើយត្រូវបានបន្ថយបង្អាក់បន្ថែមទៀតដោយសារវិបត្តិជំងឺកូវីដ-១៩ និងបញ្ហាផ្សេងៗទៀតក្នុងរយៈពេល១០ឆ្នាំចុងក្រោយ។ ជាមួយនឹងបញ្ហាប្រឈមនានាមកលើសេដ្ឋកិច្ចក្នុងតំបន់ ដូចជា កំណើនយ៉ាងឆាប់រហ័សនៃអត្រាប្រជាជនវ័យចំណាស់ ការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូររចនាសម្ព័ន្ធពាណិជ្ជកម្មពិភពលោក និន្នាការថមថយនៃកំណើនសេដ្ឋកិច្ចរបស់តំបន់ បានចោទជាសំណួរសំខាន់ៗទៅលើសមត្ថភាពរបស់តំបន់ក្នុងការគ្រប់គ្រងហានិភ័យថ្មីៗដែលកើតឡើង ទន្ទឹមនឹងការរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ចសក្តានុពលសម្រាប់រយៈពេលវែង។

កំណើនសេដ្ឋកិច្ចសក្តានុពលក្នុងតំបន់បានថមថយពីប្រមាណ ៦,០ ភាគរយនៅដើមទស្សវត្សរ៍ឆ្នាំ២០០០ ទៅ ៤,០ ភាគរយក្នុងឆ្នាំ២០២៣។ ប្រមាណ ៧០ ភាគរយនៃការថមថយនេះបណ្តាលមកពីការថយល្បឿននៃការពូនគរមូលធន ខណៈការចុះខ្សោយនៃផលិតភាពរួមនៃផលិតកម្មរួមចំណែកប្រមាណ ១០ ភាគរយ។ នៅប្រទេសមួយចំនួន ការអភិវឌ្ឍយឺតយ៉ាវនៃមូលធនមនុស្សនិងការថយចុះនៃកម្លាំងពលកម្ម ក៏បានកាត់បន្ថយសន្ទុះនៃការគាំទ្រពីកំណើនការវិនិយោគទៅលើកំណើនសេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចសក្តានុពល ត្រូវបានព្យាករថានឹងបន្តថមថយមកប្រមាណ ៣,០ ភាគរយ នៅចុងឆ្នាំ២០៥០ ឬអាចទាបជាងនេះទៀត ប្រសិនបើហានិភ័យដែលមានដូចជា ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច បរាជ័យក្នុងការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ និងការថយចុះយ៉ាងឆាប់រហ័សនៃអត្រាកំណើនប្រជាជន កើតឡើង។

ការថយល្បឿននៃផលិតភាព មួយផ្នែកគឺបណ្តាលមកពីឥទ្ធិពលដក់សល់ពីវិបត្តិជំងឺកូវីដ-១៩ ដែលប៉ះពាល់ដល់តារាងតុល្យការហិរញ្ញវត្ថុរបស់ក្រុមគ្រួសារនិងក្រុមហ៊ុន-សហគ្រាស និងល្បឿនខុសៗគ្នានៃការផ្លាស់ប្តូររចនាសម្ព័ន្ធនិងការអភិវឌ្ឍវិស័យឧស្សាហកម្មក្នុងតំបន់។ ជាពិសេស កំណើនផលិតភាពដោយសារការផ្លាស់ប្តូររចនាសម្ព័ន្ធបានធ្លាក់ចុះ ១ភាគ៣ ក្នុងរយៈពេល២ទស្សវត្សរ៍ចុងក្រោយ។ នៅក្នុងប្រទេសមួយចំនួន ការអភិវឌ្ឍវិស័យឧស្សាហកម្មបាននៅទ្រឹង ខណៈដែលសមាមាត្រនៃវិស័យឧស្សាហកម្មក្នុងចំនួនការងារនិងក្នុងផលិតកម្មពុំបានកើនឡើង។ លើសពីនេះ គម្លាតផលិតភាពតាមវិស័យ បើធៀបនឹងប្រទេសផ្សេងៗនៅលើពិភពលោក គឺមានកម្រិតខ្ពស់ ខណៈដែលការផ្លាស់ប្តូរទៅវិស័យសេវាកម្មភាគច្រើនគឺទៅសកម្មភាពសេដ្ឋកិច្ចដែលមានផលិតភាពទាប។

ប្រទេសក្នុងតំបន់មិនត្រឹមតែត្រូវប្រឈមនឹងការបំពេញកិច្ចការជាច្រើនដើម្បីស្តារកំណើនសេដ្ឋកិច្ចឡើងវិញប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវធានាថាដំណើរទៅអនាគតគឺមានភាពបត់បែន និងអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមនាពេលខាងមុខ។ បើទោះជាគ្មានរូបមន្តតែមួយ "ដែលសមស្របសម្រាប់អ្វីៗទាំងអស់" ដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយគុណភាពខ្ពស់ បទពិសោធន៍យូរឆ្នាំនៃការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ប្រទេសអាស៊ាន+៣ បានជួយផ្តល់ជាត្រីវិស័យសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍។ ទោះយ៉ាងណា យុទ្ធសាស្ត្រថ្មីនៃកំណើនសេដ្ឋកិច្ច ត្រូវរៀបចំឡើងសំដៅដោះស្រាយបញ្ហាប្រឈមថ្មីៗមកលើសេដ្ឋកិច្ច ដែលប្រទេសអាស៊ាន+៣ កំពុងជួបប្រទះ ដូចជា កម្លាំងពលកម្មដែលមានវ័យកាន់តែចំនាស់ ការប្រែប្រួលអាកាសធាតុ និងការបែកចែកភូមិសាស្ត្រសេដ្ឋកិច្ច។

ខណៈដែលអនុសាសន៍ជាក់លាក់សម្រាប់គោលនយោបាយ នឹងមានភាពខុសគ្នាទៅតាមប្រទេសនីមួយៗក្នុងតំបន់អាស៊ាន+៣ ដោយផ្អែកលើបរិបទជាក់ស្តែងរបស់ប្រទេស ជំពូកនេះបានកំណត់យកនូវគោលនយោបាយ ៥ ចំណុច ដែលអាចជាមគ្គុទ្ទេសក៍សម្រាប់អ្នកដាក់ចេញនូវគោល-នយោបាយនៃប្រទេសក្នុងតំបន់ ក្នុងការរៀបចំយុទ្ធសាស្ត្រថ្មីនៃកំណើនសម្រាប់ពេលអនាគត។ ចំណុចទាំងនេះរួមមាន (១) ការបង្កើនសមត្ថភាពក្នុងវិស័យកម្មន្តសាលដែលមានស្រាប់ ដើម្បីឆ្លើយតបនឹងនិន្នាការថ្មីនៃតម្រូវការ (២) ការផ្តល់អាទិភាពលើបម្លាស់ប្តូរទៅកាន់វិស័យសេវាកម្មដែលមានគុណភាពនិងជំនាញខ្ពស់ (៣) ការលុបបំបាត់កង្វះខាតនៃការវិនិយោគ ជាពិសេសក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធដែលបង្កើនផលិតភាព (៤) ការជំរុញនវានុវត្តន៍និងការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីកែប្រែជាថ្មីនូវដំណើរអភិវឌ្ឍន៍នាពេលកន្លងទៅ និង (៥) ការពង្រឹងសមត្ថភាពរដ្ឋ ដែលជាកត្តាពុំអាចខ្វះបានសម្រាប់ភាពជោគជ័យនៃកំណើននិងការអភិវឌ្ឍ។ ការអនុវត្តនិងសម្រេចគោលនយោបាយទាំងនេះ នឹងត្រូវគាំទ្រដោយកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំក្នុងតំបន់ ដែលនឹងជួយធានាថាតំបន់អាស៊ាន+៣ នាពេលអនាគត មិនត្រឹមតែមានកំណើនខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែជាកំណើនប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព។

*នេះជាការបកប្រែពីអត្ថបទដើមជាភាសាអង់គ្លេស ក្នុងគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ ក្នុងករណីមានភាពខុសគ្នា សូមយោងទៅអត្ថបទដើមជាភាសាអង់គ្លេស។*